រាជរដ្ឋាភិបាលកម្ពុជា

ក្រសួងមហាផ្ទៃ

លេខៈ ៤៧៥៩ ប្រក

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ប្រកាស
## ស្តីពី
## ការចុះឈ្មោះក្នុងបញ្ជីសមាគម

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងលិខិតលេខ២១៣៨ សជណ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៥ របស់ក្រសួងមហាផ្ទៃ
- យោងលិខិតលេខ៩២២-០១ ស.ឧ.ក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២ របស់សមាគមឧកញ៉ាកម្ពុជា

## សម្រេច

**ប្រការ ១.-**

ត្រូវបានចុះឈ្មោះ **សមាគមឧកញ៉ាកម្ពុជា** ឡើងវិញក្នុងបញ្ជីសមាគម នៅក្រសួងមហាផ្ទៃ ដោយមានអាសយដ្ឋានទីស្នាក់ការកណ្តាលនៅសណ្ឋាគារភ្នំពេញ អគារលេខ៥៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

**ប្រការ ២.-**

**សមាគមឧកញ៉ាកម្ពុជា** ត្រូវធ្វើសកម្មភាពស្របតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល លិខិតបទដ្ឋានគតិយុត្តនានាជាធរមាន និងលក្ខន្តិកៈរបស់ខ្លួនដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ ដោយមិនមានការរើសអើង ការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ឬសាសនាណាមួយឡើយ។

**ប្រការ ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៤.-**

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានពាក់ព័ន្ធនានា នៃក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ ប្រធាននាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ និងសាមីសមាគមដូចមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១ កើត ខែ កត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ២០២២

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ប៊ុន-ហុន

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ធនាគារជាតិ នៃកម្ពុជា
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ខុទ្ទកាល័យសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
  ( ដើម្បីជូនជ្រាប )
- ដូចប្រការ ៤ ( ដើម្បីអនុវត្ត )
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# លក្ខន្តិកៈ

## សមាគមឧកញ៉ាកម្ពុជា

## Cambodian Oknha Association

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# លក្ខន្តិកៈ
# សមាគមឧកញ៉ាកម្ពុជា
**Cambodian Oknha Association**

## ជំពូកទី ១
## ការបង្កើត ការកំណត់ឈ្មោះ វាក្យស័ព្ទ
## អត្តសញ្ញាណ ទីស្នាក់ការ សញ្ញាសម្គាល់ និងត្រា

### ប្រការ ១._ ការបង្កើត និងការកំណត់ឈ្មោះ

សមាគមនេះ ត្រូវបានបង្កើតឡើងស្របតាមមាត្រា៤២ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដោយកំណត់ឈ្មោះជាអក្សរខ្មែរថា “**សមាគមឧកញ៉ាកម្ពុជា**” សរសេរជាអក្សរកាត់ថា “**ស.ឧ.ក.**” និងឈ្មោះជាអក្សរអង់គ្លេសថា “Cambodian Oknha Association” សរសេរជាអក្សរកាត់ថា “C.O.A.”។

### ប្រការ ២._ វាក្យស័ព្ទ

វាក្យស័ព្ទ ដែលប្រើក្នុងលក្ខន្តិកៈនេះ មាននិយមន័យដូចតទៅ៖

- **ឧកញ៉ា** សំដៅដល់គោរមងារដែលត្រូវបានត្រាស់បង្គាប់ផ្តល់ដោយព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា តាមរយៈព្រះរាជក្រឹត្យ។ ឧកញ៉ា រួមមាន ឧកញ៉ា អ្នកឧកញ៉ា លោកអ្នកឧកញ៉ា និងរាល់គោរមងារជាឧកញ៉ាផ្សេងទៀតដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តជាធរមាន។
- **ភាគទាន** សំដៅដល់ប្រាក់ដែលសមាជិកម្នាក់ៗត្រូវបង់ជាប្រចាំខែ ឬប្រចាំឆ្នាំ ដែលកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់**ស.ឧ.ក.**។
- **វិភាគទាន** សំដៅដល់មូលនិធិ ឬអំណោយដោយឥតកំណត់ចំនួន ឬចំណែកដែលសមាជិក**ស.ឧ.ក.** ម្នាក់ៗ ឬច្រើននាក់ផ្តល់ជូន **ស.ឧ.ក.** តាមការស្ម័គ្រចិត្ត ដើម្បីចូលរួមទ្រទ្រង់សកម្មភាពរបស់ **ស.ឧ.ក.**។
- **បរិវិសទាន** សំដៅដល់ប្រាក់ដែលត្រូវបង់ពេលស្នើសុំចូលជាសមាជិក **ស.ឧ.ក.** លើកដំបូង ហើយការបង់នេះគឺបង់តែម្តងគត់។
- **កូរ៉ុម** សំដៅដល់ចំនួនវត្តមាន នៃសមាជិកដែលមានសិទ្ធិសម្រេច ដើម្បីឱ្យការប្រជុំ ឬសន្និបាតរបស់ **ស.ឧ.ក.** មានសុពលភាព។

**ប្រការ ៣._ អត្តសញ្ញាណ**

**ស.ឧ.ក.** គឺជាសមាគមអព្យាក្រឹត មិនស្វែងរកប្រាក់កម្រៃ និងធ្វើសកម្មភាពដោយមិនមានការរើសអើង ការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ឬសាសនាណាមួយឡើយ។

**ស.ឧ.ក.** ធ្វើជាតំណាង និងការពារផលប្រយោជន៍របស់សមាជិកខ្លួន ដោយមិនទាញយកចំណេញ ឬមិនយកកម្រៃមកចែកគ្នា។

**ប្រការ ៤._ ទីស្នាក់ការ**

**ស.ឧ.ក.** មានទីស្នាក់ការកណ្តាលស្ថិតនៅរាជធានីភ្នំពេញ និងអាចមានទីស្នាក់ការសាខា នៅតាមបណ្តាខេត្តនានាក្នុងព្រះរាជាណាចក្រកម្ពុជា តាមការចាំបាច់ស្របតាមភាពរីកចម្រើនរបស់**ស.ឧ.ក.**។

ការផ្លាស់ប្តូរអាសយដ្ឋានទីស្នាក់ការកណ្តាល ព្រមទាំងការបើក ការផ្លាស់ប្តូរ និងការបិទទីស្នាក់ការសាខារបស់**ស.ឧ.ក.**អាចធ្វើបានក្នុងករណីចាំបាច់ ដោយត្រូវអនុវត្តទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

**ប្រការ ៥ ._ សញ្ញាសម្គាល់ និងត្រា**

**ស.ឧ.ក.** មានសញ្ញាសម្គាល់ និងត្រាដូចមានកំណត់នៅក្នុង(ឧបសម្ព័ន្ធទី២) នៃលក្ខន្តិកៈនេះ។ ត្រារបស់**ស.ឧ.ក.** មានសណ្ឋានជារង្វង់មូលទំហំ ៣៤(សាមសិបបួន)មីលីម៉ែត្រ និងកំណត់ប្រើនូវប្រភេទទឹកត្រាពណ៌ខៀវ។

## ជំពូកទី ២

## ចក្ខុវិស័យ គោលបំណង និងបេសកកម្ម

**ប្រការ ៦._ ចក្ខុវិស័យ**

**ស.ឧ.ក.** ចង់ឃើញឧត្តមភាពដ៏ឧត្តុងឧត្តម នៃគោរមងារឧកញ៉ា ក្នុងការចូលរួមអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជាប្រកបដោយចីរភាព និងបរិយាបន្ន ដើម្បីទទួលបាននូវភាពសុខសាន្ត សុខដុមនីយកម្ម និងការរីកចម្រើនខាងកម្រិតជីវភាពរបស់ប្រជាពលរដ្ឋកម្ពុជាល្អប្រសើរដូចបណ្តាប្រទេសអភិវឌ្ឍន៍នានា ដោយចូលរួមចំណែកគ្រប់វិស័យជាមួយស្ថាប័នជាតិ និងអន្តរជាតិ។

**ប្រការ ៧._ គោលបំណង**

**ស.ឧ.ក.** មានគោលបំណងលើកកម្ពស់គុណតម្លៃ នៃគោរមងារឧកញ៉ា និងធានាបាននូវសេចក្តីថ្លៃថ្នូរ សីលធម៌ និងសាមគ្គីភាពរឹងមាំរបស់ឧកញ៉ា ដើម្បីជាមូលដ្ឋានក្នុងការរួមចំណែកយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជា សំដៅចូលរួមកសាង និងអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជា ស្របតាមគោលនយោបាយយុទ្ធសាស្ត្រចតុកោណ ទាំងក្នុងក្របខណ្ឌជាតិ និងអន្តរជាតិ ជាពិសេសសកម្មភាពសង្គមកិច្ច មនុស្សធម៌ និងសប្បុរសធម៌ ដើម្បីធានាបាននូវភាពសុខសាន្ត សុខដុមនីយកម្ម និងការរីកចម្រើនរបស់ប្រជាជនកម្ពុជា ប្រកបដោយចីរភាព និងបរិយាបន្ន។

**ប្រការ ៨._ បេសកកម្ម**

**ស.ឧ.ក.** មានបេសកកម្មសំខាន់ ដូចខាងក្រោម៖

- ធ្វើជាតំណាង និងការពារផលប្រយោជន៍ និងកិត្តិយសរបស់ឧកញ៉ាដែលជាសមាជិក **ស.ឧ.ក.**
- កសាងទំនាក់ទំនងឱ្យមានភាពស្និទ្ធស្នាលប្រកបដោយមិត្តភាព សាមគ្គីភាព សហប្រតិបត្តិការ ដោយបង្ហាញនូវឆន្ទៈពិតប្រាកដ ដើម្បីបង្កើតឱ្យមានជំនឿទុកចិត្តគ្នាក្នុងភាពជាមហាគ្រួសារឧកញ៉ា
- បង្រួបបង្រួមមហាគ្រួសារឧកញ៉ាកម្ពុជា ដើម្បីរក្សាទំនាក់ទំនង ការផ្លាស់ប្តូរព័ត៌មាន ការពិគ្រោះយោបល់អំពីតម្រូវការចាំបាច់ ក្នុងការជួយគ្នាទៅវិញទៅមក
- ចូលរួមចំណែកក្នុងសកម្មភាពសង្គម និងសប្បុរសធម៌នានា ដើម្បីបង្កើនកិត្យានុភាព ឧត្តមភាព និងគុណធម៌របស់ឧកញ៉ាឱ្យកាន់តែរីកម្រើន និងឆ្ពោះទៅកាន់វឌ្ឍនភាពដ៏ល្អប្រពៃ រុងរឿងខ្ពង់ខ្ពស់នាពេលអនាគត
- លើកកម្ពស់ការគោរពច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានានៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ជំរុញ និងផ្សព្វផ្សាយសក្តានុពល កាលានុវត្តភាព និងនវានុវត្តន៍ថ្មីៗក្នុងព្រះរាជាណាចក្រកម្ពុជា
- បង្កើតវេទិកា សិក្ខាសាលា ពិព័រណ៍បង្ហាញស្នាដៃថ្មីៗ និងការផ្លាស់ប្តូរបទពិសោធន៍ពាក់ព័ន្ធនឹង ធុរកិច្ច ពាណិជ្ជកម្ម ការវិនិយោគ និងវិស័យដទៃទៀត ដែលជាគុណប្រយោជន៍សម្រាប់សង្គម និងសេដ្ឋកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ៣

## សមាជិកភាព សិទ្ធិ ភារកិច្ច និងបុគ្គលិកភាព

**ប្រការ ៩._ សមាជិកភាព**

ឧកញ៉ាទាំងឡាយមានសិទ្ធិស្នើសុំចូលជាសមាជិក**ស.ឧ.ក.** បាន។ សមាជិកភាព ត្រូវបានកំណត់ចំនួន ៣ (បី) ប្រភេទ ដូចខាងក្រោម៖

- **សមាជិកស្ថាបនិក**៖ ឧកញ៉ាទាំងឡាយដែលបានចូលរួមផ្តួចផ្តើមគំនិត កម្លាំងកាយ កម្លាំងប្រាជ្ញា សម្ភារ និងថវិកា ដើម្បីរៀបចំបង្កើត**ស.ឧ.ក.**។ សមាជិកស្ថាបនិកនៃ **ស.ឧ.ក.** មានចំនួន ២៧ (ម្ភៃប្រាំពីរ) រូប ដូចមានកំណត់ក្នុង(ឧបសម្ព័ន្ធទី១) នៃលក្ខន្តិកៈនេះ។
- **សមាជិកសកម្ម**៖ ឧកញ៉ាទាំងឡាយដែលចូលរួមបំពេញការងារក្នុងរចនាសម្ព័ន្ធ ឬក្រុមការងារនានា របស់ **ស.ឧ.ក.** ឬដែលត្រូវបានតែងតាំងដោយក្រុមប្រឹក្សាភិបាល។
- **សមាជិកទ្រទ្រង់**៖ ឧកញ៉ាផ្សេងទៀតដែលមិនមែនជាសមាជិកស្ថាបនិក និងសមាជិកសកម្ម។

សមាជិកទាំងអស់នៃ **ស.ឧ.ក.** ត្រូវគោរពច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងរាល់សេចក្តីសម្រេចរបស់ **ស.ឧ.ក.** ជាដាច់ខាត។

លក្ខខណ្ឌតម្រូវ នៃសមាជិកភាព និងនីតិវិធីនៃការសុំចូលជាសមាជិក ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ **ស.ឧ.ក.**។

គម្រូ នៃពាក្យសុំចូលជាសមាជិក និងពាក្យសុំលាឈប់ពីសមាជិក នៃ**ស.ឧ.ក.** មានភ្ជាប់មកជាមួយនូវលក្ខន្តិកៈនេះ។

**ប្រការ ១០._ ការបាត់បង់សមាជិកភាព**

សមាជិករបស់ **ស.ឧ.ក.** ត្រូវបាត់បង់សមាជិកភាព ដោយមូលហេតុដូចខាងក្រោម៖

- ការបាត់បង់គោរមងារជាឧកញ៉ា។
- សាមីខ្លួនទទួលមរណភាព។
- សាមីខ្លួនត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលមានសាលក្រម ឬសាលដីកាស្ថាពរដោយតុលាការក្នុងព្រះរាជាណាចក្រកម្ពុជា។
- មានជំងឺវិបល្លាសស្មារតី ឬវិកលចរិត ដែលមានលិខិតបញ្ជាក់ចេញដោយមន្ទីរពេទ្យ ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។
- សាមីខ្លួនបានសុំលាឈប់ជាលាយលក្ខណ៍អក្សរពីសមាជិកភាព នៃ**ស.ឧ.ក.** ដោយត្រូវបានដាក់ជូនអគ្គលេខាធិការដ្ឋានឱ្យបាន ១៥ (ដប់ប្រាំ) ថ្ងៃ នៅមុនថ្ងៃឈប់ពីសមាជិកភាព។

**ប្រការ ១១._ ការដកហូតសមាជិកភាព**

សមាជិករបស់ **ស.ឧ.ក.** អាចត្រូវដកហូតសមាជិកភាព ដោយមូលហេតុដូចខាងក្រោម៖

- បំពានយ៉ាងធ្ងន់ធ្ងរលើបទប្បញ្ញត្តិនៃលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ឬសេចក្តីសម្រេចនានារបស់ **ស.ឧ.ក.**។
- មិនបានអនុវត្តតាមលក្ខខណ្ឌណាមួយ នៃលក្ខខណ្ឌតម្រូវសមាជិកភាព ដូចដែលមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់ **ស.ឧ.ក.**។

ការសម្រេចដកហូតសមាជិកភាពនៃ **ស.ឧ.ក.** ត្រូវធ្វើឡើងតាមរយៈសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ដោយសំឡេងគាំទ្រ ២/៣ (ពីរភាគបី) នៃចំនួនសមាសភាពក្រុមប្រឹក្សាភិបាល តាមសំណើរបស់គណៈកម្មការសមាជិកភាព វិន័យ និងក្រមសីលធម៌។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលក្នុងការដកហូតសមាជិកភាពនៃ **ស.ឧ.ក.** ជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។

**ប្រការ ១២._ សិទ្ធិរបស់សមាជិក**

សមាជិកទាំងអស់នៃ **ស.ឧ.ក.** មានសិទ្ធិដូចខាងក្រោម៖

- ចូលរួមពិភាក្សា ផ្តល់យោបល់ និងអនុម័តរាល់គោលការណ៍ និងសេចក្តីសម្រេចនានារបស់ **ស.ឧ.ក.** នៅក្នុងសន្និបាត
- បោះឆ្នោតជ្រើសរើសសមាសភាពក្រុមប្រឹក្សាភិបាល
- ចូលរួមសកម្មភាពផ្សេងៗរបស់ **ស.ឧ.ក.**។

សមាជិកស្ថាបនិក និងសមាជិកសកម្មអាចឈរឈ្មោះជាបេក្ខជនសម្រាប់សមាសភាពក្រុមប្រឹក្សាភិបាល។

**ប្រការ ១៣._ ភារកិច្ចសមាជិក**

សមាជិកទាំងអស់នៃ **ស.ឧ.ក.** មានភារកិច្ចដូចខាងក្រោម៖

- ប្រតិបត្តិតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងសេចក្តីសម្រេចនានារបស់ **ស.ឧ.ក.**
- បង់ភាគទាន ឬបរិវិសទាន ដែលកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ **ស.ឧ.ក.**
- អនុវត្តសកម្មភាពផ្សេងៗតាមការបែងចែកភារកិច្ច ឬការចាត់តាំងរបស់ប្រធាន **ស.ឧ.ក.**។

**ប្រការ ១៤._ ការជ្រើសរើស និងការបញ្ឈប់បុគ្គលិក**

**ស.ឧ.ក.** អាចជ្រើសរើសបុគ្គលិកឱ្យចូលបម្រើការងារទៅតាមការចាំបាច់របស់ខ្លួន និងត្រូវអនុវត្តតាមរយៈការប្រឡង ឬការធ្វើតេស្ត។ បុគ្គលិករបស់ **ស.ឧ.ក.** ត្រូវចុះកិច្ចសន្យាការងារដោយអនុលោមទៅតាមច្បាប់ស្តីពីការងារ ច្បាប់ស្តីពីអន្តោប្រវេសន៍ លិខិតបទដ្ឋានគតិយុត្តនានាជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា និងបទបញ្ជាផ្ទៃក្នុងរបស់**ស.ឧ.ក.** ដើម្បីបំពេញកិច្ចការតាមមុខតំណែង និងភារកិច្ចដូចបានកំណត់ក្នុង លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងសេចក្តីសម្រេចនានារបស់**ស.ឧ.ក.**។

បុគ្គលិករបស់**ស.ឧ.ក.** មិនត្រូវបានអនុញ្ញាតឱ្យយកឈ្មោះរបស់**ស.ឧ.ក.** ទៅប្រើប្រាស់ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន។

ការបញ្ឈប់បុគ្គលិករបស់ **ស.ឧ.ក.** ត្រូវធ្វើឡើងស្របតាមកិច្ចសន្យាការងារ ច្បាប់ស្តីពីការងារ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ៤
## រចនាសម្ព័ន្ធដឹកនាំ តួនាទី ភារកិច្ច និងការគ្រប់គ្រង

**ប្រការ ១៥._ រចនាសម្ព័ន្ធដឹកនាំ**

**ស.ឧ.ក.** មានរចនាសម្ព័ន្ធដឹកនាំ ដូចខាងក្រោម៖

- សន្និបាត
- ឧត្តមក្រុមប្រឹក្សាជាន់ខ្ពស់
- ក្រុមប្រឹក្សាភិបាល
- គណៈកម្មការជំនាញ
- អគ្គលេខាធិការដ្ឋាន។

### ផ្នែកទី ១
### សន្និបាត

**ប្រការ ១៦._ សន្និបាត**

សន្និបាត គឺជាអង្គការលេខខ្ពស់បំផុតរបស់ **ស.ឧ.ក.** ដែលសមាជិកទាំងអស់នៃ **ស.ឧ.ក.** អាចចូលរួមដើម្បីអនុម័តសម្រេចលើកិច្ចការដែលមានសារៈសំខាន់ជាមូលដ្ឋានគ្រឹះនៃ **ស.ឧ.ក.**។

សន្និបាត **ស.ឧ.ក.** មានពីរប្រភេទ គឺសន្និបាតសាមញ្ញ និងសន្និបាតវិសាមញ្ញ។

**ប្រការ ១៧._ សន្និបាតសាមញ្ញ**

សន្និបាតសាមញ្ញ ត្រូវរៀបចំឡើងជារៀងរាល់ឆ្នាំ នៅក្នុងសប្តាហ៍ណាមួយក្នុងខែធ្នូ នៃឆ្នាំនីមួយៗ ដោយមានការចូលរួមពីសមាជិករបស់ **ស.ឧ.ក.** តាមការអញ្ជើញរបស់ប្រធាន **ស.ឧ.ក.**។

របៀបវារៈ ទីកន្លែង និងពេលវេលា នៃសន្និបាត ត្រូវអនុម័តដោយក្រុមប្រឹក្សាភិបាល និងត្រូវជូនដំណឹងទៅសមាជិក យ៉ាងតិចបំផុត១៥ (ដប់ប្រាំ) ថ្ងៃ មុនថ្ងៃសន្និបាត។

សន្និបាតសាមញ្ញ មានភារកិច្ចដូចតទៅៈ

- ជ្រើសតាំងសមាសភាពក្រុមប្រឹក្សាភិបាល នៅពេលចប់អាណត្តិ
- ពិនិត្យ និងអនុម័តលើរបាយការណ៍សកម្មភាព និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលអនុវត្តកន្លងមក
- ពិនិត្យ និងអនុម័តលើផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព
- ពិនិត្យ និងអនុម័តលើការកំណត់ទិសដៅសកម្មភាព និងគម្រោងថវិកាសម្រាប់ឆ្នាំបន្ទាប់
- ពិនិត្យ និងអនុម័តលើការផ្លាស់ប្តូរ ឬការធ្វើវិសោធនកម្មលក្ខន្តិកៈរបស់ **ស.ឧ.ក.**
- ពិនិត្យ និងអនុម័តលើការរំលាយ **ស.ឧ.ក.** និងការចាត់ចែងធនធាន និងទ្រព្យសម្បត្តិរបស់ **ស.ឧ.ក.** ក្រោយពេលរំលាយ។

## ប្រការ ១៨._ សន្និបាតវិសាមញ្ញ

សន្និបាតវិសាមញ្ញ អាចរៀបចំឡើងតាមការចាំបាច់ ក្នុងចន្លោះនៃសន្និបាតសាមញ្ញ តាមសំណើរបស់ប្រធាន **ស.ឧ.ក.** ឬតាមសំណើសុំក្នុងចំនួន២/៣ (ពីរភាគបី) នៃសមាសភាពក្រុមប្រឹក្សាភិបាល។

របៀបវារៈ ទីកន្លែង និងពេលវេលា នៃសន្និបាត ត្រូវអនុម័តដោយក្រុមប្រឹក្សាភិបាល និងត្រូវជូនដំណឹងទៅសមាជិក យ៉ាងតិចបំផុត ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃសន្និបាត។

សន្និបាតវិសាមញ្ញ មានភារកិច្ចដូចតទៅៈ

- ពិនិត្យ និងអនុម័តលើការផ្លាស់ប្តូរសមាសភាពក្រុមប្រឹក្សាភិបាល
- ពិនិត្យ និងអនុម័តលើការផ្លាស់ប្តូរ ឬការធ្វើវិសោធនកម្មលក្ខន្តិកៈរបស់ **ស.ឧ.ក.**
- ពិនិត្យ និងអនុម័តលើទិសដៅសកម្មភាពការងារ ឬគម្រោងថវិកាបន្ថែម ក្នុងករណីចាំបាច់
- ពិនិត្យ និងអនុម័តលើការរំលាយ **ស.ឧ.ក.** និងការចាត់ចែងធនធាន និងទ្រព្យសម្បត្តិរបស់ **ស.ឧ.ក.** ក្រោយពេលរំលាយ
- ពិនិត្យ និងអនុម័តលើកិច្ចការចាំបាច់នានា ដែលស្នើដោយក្រុមប្រឹក្សាភិបាល។

## ប្រការ ១៩._ កូរ៉ុម

សន្និបាតសាមញ្ញ និងសន្និបាតវិសាមញ្ញ អាចយកជាការបានលុះត្រាតែមាន កូរ៉ុមចំនួនលើសពី២/៣ (ពីរភាគបី) នៃចំនួនសមាសភាពក្រុមប្រឹក្សាភិបាល សម្រាប់ការកោះអញ្ជើញលើកទី១។

ក្នុងករណីកូរ៉ុមពុំគ្រប់ចំនួនកំណត់ដើម្បីដំណើរការសន្និបាតតាមការកោះអញ្ជើញលើកទី១ ការកោះអញ្ជើញលើកទី២ ត្រូវធ្វើឡើងក្នុងរយៈពេល៧ (ប្រាំពីរ) ថ្ងៃ នៅក្រោយកាលបរិច្ឆេទលើកទី១ នៃសន្និបាត។ សន្និបាតដែលត្រូវធ្វើឡើងតាមការកោះអញ្ជើញលើកទី២នេះ ត្រូវមានកូរ៉ុមចំនួនលើសពី២/៣ (ពីរភាគបី) នៃចំនួនសមាសភាពក្រុមប្រឹក្សាភិបាល។

ក្នុងករណីកូរ៉ុមពុំគ្រប់ចំនួនកំណត់សម្រាប់ដំណើរការសន្និបាតតាមការកោះអញ្ជើញលើកទី២ ការកោះអញ្ជើញលើកទី៣ ត្រូវធ្វើឡើងក្នុងរយៈពេល៧ (ប្រាំពីរ) ថ្ងៃ នៅក្រោយកាលបរិច្ឆេទលើកទី២ នៃសន្និបាត។ សន្និបាតដែលត្រូវធ្វើឡើងតាមការកោះអញ្ជើញលើកទី៣នេះ អាចដំណើរការបានដោយមិនគិតពីកូរ៉ុមឡើយ។

**ប្រការ ២០._ សេចក្តីសម្រេច**

រាល់សេចក្តីសម្រេចនៃសន្និបាតសាមញ្ញ និងសន្និបាតវិសាមញ្ញ ត្រូវធ្វើឡើងដោយការបោះឆ្នោតអនុម័តសម្រេចដោយសំឡេងគាំទ្រចំនួន ៥០%+១ (ហាសិបភាគរយបូកមួយ) នៃចំនួនសមាជិក **ស.ឧ.ក.** ដែលមានវត្តមាន។

## ផ្នែកទី២

## ឧត្តមក្រុមប្រឹក្សាជាន់ខ្ពស់

**ប្រការ ២១._ ឧត្តមក្រុមប្រឹក្សាជាន់ខ្ពស់**

**ស.ឧ.ក.** មានឧត្តមក្រុមប្រឹក្សាជាន់ខ្ពស់ នៃ **ស.ឧ.ក.** ជាមគ្គុទ្ទេសក៍ក្នុងការផ្តល់អនុសាសន៍ល្អៗ បទពិសោធន៍ នៃការដឹកនាំជូនដល់**ស.ឧ.ក.**។ ឧត្តមក្រុមប្រឹក្សាជាន់ខ្ពស់ រួមមាន៖

- ប្រធានកិត្តិយស
- អនុប្រធានកិត្តិយស
- ទីប្រឹក្សាជាន់ខ្ពស់។

**១.ប្រធានកិត្តិយស** ÷ ជាឥស្សរជនជាន់ខ្ពស់បំផុត នៃរាជរដ្ឋាភិបាល ដែលត្រូវបានគោរពស្នើសុំការអនុញ្ញាត និងគោរពអញ្ជើញដោយផ្ទាល់ពីប្រធានក្រុមប្រឹក្សាភិបាលក្នុងអាណត្តិ។

**២.អនុប្រធានកិត្តិយស** ÷ ប្រធាន **ស.ឧ.ក.** ដែលបានចប់អាណត្តិ និងដែលមិនត្រូវបានបោះឆ្នោតជ្រើសរើសជាថ្មី ត្រូវបានតែងតាំងជាអនុប្រធានកិត្តិយស។

**៣.ទីប្រឹក្សាជាន់ខ្ពស់** ÷ ជាឥស្សរជនជាន់ខ្ពស់ នៃក្រសួង ស្ថាប័ននានា ដែលត្រូវបានគោរពស្នើសុំការអនុញ្ញាត និងគោរពអញ្ជើញដោយផ្ទាល់ពីប្រធានក្រុមប្រឹក្សាភិបាលក្នុងអាណត្តិ។

## ផ្នែកទី ៣

## ក្រុមប្រឹក្សាភិបាល

**ប្រការ ២២._ សមាសភាពក្រុមប្រឹក្សាភិបាល**

**ស.ឧ.ក.** ត្រូវដឹកនាំ និងគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាល ដែលមានប្រធាន ១ (មួយ) រូប និងអមដោយអនុប្រធានមួយចំនួនតាមការចាំបាច់ ព្រមទាំងសមាជិកដែលជាសមាជិកស្ថាបនិក ឬសមាជិកសកម្មរបស់ **ស.ឧ.ក.**។ សមាសភាពក្រុមប្រឹក្សាភិបាលមានចំនួនយ៉ាងតិច ២៧ (ម្ភៃប្រាំពីរ) រូប។

ប្រធានក្រុមប្រឹក្សាភិបាល គឺជាប្រធាន **ស.ឧ.ក.** និងជាតំណាងស្របច្បាប់របស់**ស.ឧ.ក.** ដែលមានតួនាទីជាអ្នកទទួលបន្ទុកការងាររួម និងទទួលខុសត្រូវលើសកម្មភាពរបស់ **ស.ឧ.ក.**។

## ប្រការ ២៣._ ការជ្រើសរើសសមាសភាពក្រុមប្រឹក្សាភិបាល

សមាសភាពក្រុមប្រឹក្សាភិបាល ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតអនុម័តសម្រេចដោយសន្និបាតរបស់ **ស.ឧ.ក.** ក្នុងសំឡេងគាំទ្រ៥០%+១ (ហាសិបភាគរយបូកមួយ) នៃចំនួនសមាជិក **ស.ឧ.ក.** ដែលមានវត្តមាន។

ក្រុមប្រឹក្សាភិបាល មានអាណត្តិ ៥ (ប្រាំ) ឆ្នាំ។ ចំពោះការជ្រើសរើសប្រធាន និងអនុប្រធានក្រុមប្រឹក្សាភិបាល សម្រាប់អាណត្តិនីមួយៗ ត្រូវសម្រេចជ្រើសរើសឡើងដោយសំឡេងគាំទ្រជាឯកច្ឆន្ទ នៃសមាសភាពក្រុមប្រឹក្សាភិបាលដែលបានជាប់ឆ្នោត នៅក្នុងរបៀបវារៈបន្ទាប់នៃសន្និបាត។

ប្រធានក្រុមប្រឹក្សាភិបាលដែលចប់អាណត្តិ អាចឈរឈ្មោះបោះឆ្នោតសារជាថ្មីបាន និងអាចបំពេញមុខងារជាប្រធានក្រុមប្រឹក្សាភិបាលបានត្រឹមតែ២(ពីរ)អាណត្តិតែប៉ុណ្ណោះ។

សមាសភាពក្រុមប្រឹក្សាភិបាលចាស់ ត្រូវបំពេញមុខងាររបស់ខ្លួន រហូតដល់មានការជ្រើសរើសសមាសភាពថ្មីនៃក្រុមប្រឹក្សាភិបាល។

## ប្រការ ២៤._ គណៈកម្មការរៀបចំការបោះឆ្នោតជ្រើសរើសសមាសភាពក្រុមប្រឹក្សាភិបាល

ការបោះឆ្នោតជ្រើសរើសសមាសភាពក្រុមប្រឹក្សាភិបាល ត្រូវរៀបចំឡើងដោយគណៈកម្មការរៀបចំការបោះឆ្នោត។ ការបង្កើតគណៈកម្មការរៀបចំការបោះឆ្នោត និងការតែងតាំងសមាសភាពគណៈកម្មការរៀបចំការបោះឆ្នោត ត្រូវជ្រើសរើសចេញមកពីសមាសភាពគណៈកម្មការជំនាញនានា តាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

## ប្រការ ២៥._ ការបាត់បង់មុខងារ និងការបញ្ចប់មុខងារពីសមាសភាពក្រុមប្រឹក្សាភិបាល

សមាសភាពក្រុមប្រឹក្សាភិបាល ដែលមិនបានចូលរួមប្រជុំចំនួន ៣ (បី) ដង ដោយមិនបានជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនទៅប្រធានក្រុមប្រឹក្សាភិបាល ត្រូវបានកំណត់ថាលះបង់មុខងាររបស់ខ្លួន និងត្រូវបញ្ចប់មុខងារពីសមាសភាពក្រុមប្រឹក្សាភិបាល ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

សមាសភាពក្រុមប្រឹក្សាភិបាល ដែលបានបំពានយ៉ាងធ្ងន់ធ្ងរលើបទប្បញ្ញត្តិនៃលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ឬសេចក្តីសម្រេចនានារបស់ **ស.ឧ.ក.** អាចត្រូវបញ្ចប់មុខងារនៅមុនអាណត្តិ ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល តាមសំណើរបស់គណៈកម្មការសមាជិកភាព វិន័យ និងក្រមសីលធម៌។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលដែលមានចែងក្នុងកថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃប្រការនេះ ជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។

សមាសភាពក្រុមប្រឹក្សាភិបាល អាចស្នើសុំលាលែងពីមុខងាររបស់ខ្លួនករណីពុំមានលទ្ធភាព ឬ សមត្ថភាពបំពេញតួនាទីរបស់ខ្លួនបាន ដោយត្រូវធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅប្រធានក្រុមប្រឹក្សាភិបាល ក្នុងរយៈពេលយ៉ាងតិច ២ (ពីរ) ខែ។ ក្នុងករណីនេះ មុខងារជាសមាសភាពក្រុមប្រឹក្សាភិបាល ត្រូវបានបាត់បង់ចាប់ពីកាលបរិច្ឆេទដែលកំណត់ក្នុងលិខិតជូនដំណឹងអំពីការលាលែងពីមុខងារ។ ក្នុងករណី ដែលមិនមានការកំណត់កាលបរិច្ឆេទអំពីការលាលែងពីមុខងារនៅក្នុងលិខិតជូនដំណឹង មុខងារជាសមាសភាពក្រុមប្រឹក្សា-

ភិបាលនឹងត្រូវបាត់បង់នៅកាលបរិច្ឆេទចុងក្រោយ នៃរយៈពេល ២ (ពីរ) ខែ គិតចាប់ពីថ្ងៃដែលប្រធានក្រុមប្រឹក្សាភិបាលបានទទួលនូវលិខិតជូនដំណឹង។

មរណភាពរបស់សមាសភាពក្រុមប្រឹក្សាភិបាល នាំឱ្យមានការបាត់បង់មុខងារជាសមាសភាពក្រុមប្រឹក្សាភិបាលរបស់បុគ្គលនោះជាស្វ័យប្រវត្តិ។

**ប្រការ ២៦._ ការផ្លាស់ប្តូរសមាសភាពក្រុមប្រឹក្សាភិបាល**

សមាសភាពក្រុមប្រឹក្សាភិបាល ដែលបានបាត់បង់មុខងារជាសមាសភាពក្រុមប្រឹក្សាភិបាលស្របតាមប្រការ២៥ នៃលក្ខន្តិកៈនេះ នឹងត្រូវជំនួសជាបណ្តោះអាសន្នដោយសមាជិកស្ថាបនិក ឬសមាជិកសកម្មដែលត្រូវបានចាត់តាំងដោយក្រុមប្រឹក្សាភិបាល រហូតដល់មានការបោះឆ្នោតផ្លាស់ប្តូរសមាសភាពក្រុមប្រឹក្សាភិបាលស្របតាមប្រការ១៨ នៃលក្ខន្តិកៈនេះ។ សមាសភាពក្រុមប្រឹក្សាភិបាលដែលបានផ្លាស់ប្តូរនេះ ត្រូវបំពេញមុខងាររបស់ខ្លួនរហូតដល់មានការជ្រើសរើសក្រុមប្រឹក្សាភិបាលថ្មី សម្រាប់អាណត្តិបន្ទាប់។

**ប្រការ ២៧._ កិច្ចប្រជុំក្រុមប្រឹក្សាភិបាល**

ក្រុមប្រឹក្សាភិបាល ត្រូវរៀបចំកិច្ចប្រជុំនៅរៀងរាល់ ៣ (បី) ខែម្តង តាមការកោះអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាភិបាល។ ក្នុងករណីចាំបាច់ ប្រធានក្រុមប្រឹក្សាភិបាល អាចកោះប្រជុំក្រុមប្រឹក្សាភិបាលជាវិសាមញ្ញ។ ក្នុងករណីមានធុរៈចាំបាច់ ប្រធានក្រុមប្រឹក្សាភិបាល អាចផ្ទេរសិទ្ធិទៅឱ្យអនុប្រធានក្រុមប្រឹក្សាភិបាលណាម្នាក់ ដើម្បីកោះអញ្ជើញ និង/ឬដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាភិបាល តាមរយៈលិខិតផ្ទេរសិទ្ធិ។

របៀបវារៈ ទីកន្លែង និងពេលវេលានៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ត្រូវផ្ញើជូនសមាសភាពក្រុមប្រឹក្សាភិបាលយ៉ាងតិចបំផុត៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃប្រជុំ។ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលអាចត្រូវបានធ្វើឡើងក្នុងទម្រង់ជាអាទិ៍ដោយផ្ទាល់ ឬតាមរយៈប្រព័ន្ធវីដេអូ ឬវេទិកានិម្មិតផ្សេងទៀត។

កិច្ចប្រជុំក្រុមប្រឹក្សាភិបាលមានតម្លៃគតិយុត្ត លុះត្រាតែមានកូរ៉ុម ២/៣ (ពីរភាគបី) នៃចំនួនសមាសភាពក្រុមប្រឹក្សាភិបាល។

រាល់សេចក្តីសម្រេចនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ត្រូវធ្វើឡើងដោយសំឡេងគាំទ្រ ៥០%+១ (ហាសិបភាគរយបូកមួយ) នៃចំនួនសមាសភាពក្រុមប្រឹក្សាភិបាល។ ប៉ុន្តែ សេចក្តីសម្រេច នៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ត្រូវធ្វើឡើងដោយសំឡេងគាំទ្រ ២/៣ (ពីរភាគបី) នៃចំនួនសមាសភាពក្រុមប្រឹក្សាភិបាល ចំពោះករណីដូចខាងក្រោម៖

- ពិនិត្យ និងអនុម័តលើការផ្លាស់ប្តូរ ឬការធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងរបស់ **ស.ឧ.ក.**
- ពិនិត្យ និងអនុម័តដកហូតសមាជិកភាពពីសមាជិកណាម្នាក់
- ពិនិត្យ និងអនុម័តបញ្ចប់មុខងារសមាសភាពក្រុមប្រឹក្សាភិបាលណាម្នាក់ នៅមុនចប់អាណត្តិ។

**ប្រការ ២៨._ សេចក្តីសម្រេចជាលាយលក្ខណ៍អក្សររបស់ក្រុមប្រឹក្សាភិបាល**

ក្រៅពីការធ្វើសេចក្តីសម្រេចតាមរយៈកិច្ចប្រជុំ សមាសភាពក្រុមប្រឹក្សាភិបាលអាចធ្វើសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដោយការចុះហត្ថលេខា ឬស្នាមមេដៃ នៅលើសេចក្តីព្រាងនៃសេចក្តីសម្រេចដែលបានផ្ញើជូនដោយប្រធានក្រុមប្រឹក្សាភិបាល។ សមាសភាពក្រុមប្រឹក្សាភិបាលទាំងអស់ ត្រូវទទួលបានសំណុំរឿងនៃ

សេចក្តីសម្រេចដែលត្រូវស្នើសុំការពិនិត្យ និងការសម្រេច។ ក្នុងករណីនេះ រាល់សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ត្រូវធ្វើឡើងដោយមានការគាំទ្រក្នុងចំនួន ២/៣ (ពីរភាគបី) នៃសមាសភាពក្រុមប្រឹក្សាភិបាល។

សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដោយការចុះហត្ថលេខា ឬស្នាមមេដៃរបស់សមាសភាពក្រុមប្រឹក្សាភិបាល ត្រូវមានសុពលភាពគតិយុត្តដូចគ្នានឹងសេចក្តីសម្រេច ដែលបានអនុម័តនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សា-ភិបាល។

## ប្រការ ២៩._ តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល មានតួនាទី និងភារកិច្ច ដូចតទៅ៖

- រៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រអំពីការគ្រប់គ្រង និងចាត់ចែងកិច្ចការរបស់ **ស.ឧ.ក.**
- ដឹកនាំអនុវត្ត និងណែនាំអំពីកម្មវិធីការងារ និងសកម្មភាព ដែលអនុម័តដោយសន្និបាតរបស់ **ស.ឧ.ក.**
- ពិភាក្សា និងអនុម័តលើរបាយការណ៍ស្តីពីសកម្មភាពការងារ របាយការណ៍ហិរញ្ញវត្ថុ និងទិសដៅការងារពីសម័យប្រជុំមួយទៅសម័យប្រជុំមួយទៀត
- អនុម័តដកហូតសមាជិកភាពពីសមាជិកណាម្នាក់
- អនុម័តបញ្ចប់សមាសភាពក្រុមប្រឹក្សាភិបាលណាម្នាក់ នៅមុនចប់អាណត្តិ
- ពិភាក្សា និងអនុម័តលើបេក្ខភាពប្រធាន និងសមាសភាពផ្សេងទៀត នៃគណៈកម្មការជំនាញ
- ពិភាក្សា និងអនុម័តលើបេក្ខភាពអគ្គលេខាធិការ និងអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន ព្រមទាំងប្រធាន និងអនុប្រធាន នៃនាយកដ្ឋានចំណុះនានាឱ្យអគ្គលេខាធិការដ្ឋាន
- ពិភាក្សា និងអនុម័តលើសមាសភាពគណៈកម្មការរៀបចំការបោះឆ្នោត
- រៀបចំ និងអនុម័តបទបញ្ជា និងនីតិវិធីនៃការបោះឆ្នោតជ្រើសរើសសមាសភាពក្រុមប្រឹក្សាភិបាល
- សម្រេចកោះប្រជុំ និងកំណត់របៀបវារៈ ព្រមទាំងទីកន្លែងនៃសន្និបាតរបស់ **ស.ឧ.ក.**
- រៀបចំ និងអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ **ស.ឧ.ក.**
- កំណត់ផែនការយុទ្ធសាស្ត្រ និងផែនការការងារពាក់ព័ន្ធនឹងការងារក្រៅប្រទេស
- គ្រប់គ្រង និងចាត់ចែងធនធាន និងទ្រព្យសម្បត្តិទាំងអស់របស់ **ស.ឧ.ក.**
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការងារស្របតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងសេចក្តីសម្រេចនានារបស់ **ស.ឧ.ក.**
- ផ្តល់ប័ណ្ណសរសើរ និងប័ណ្ណលើកទឹកចិត្តចំពោះសមាជិករបស់ **ស.ឧ.ក.** ដែលមានស្នាដៃឆ្នើម។

## ប្រការ ៣០._ តួនាទី និងភារកិច្ចរបស់ប្រធានក្រុមប្រឹក្សាភិបាល

ប្រធានក្រុមប្រឹក្សាភិបាល មានតួនាទី និងភារកិច្ច ដូចតទៅ៖

- ធានានិរន្តរភាពការងារដើម្បីសម្រេចឱ្យបានប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព នូវរាល់បេសកកម្ម គោលបំណង និងចក្ខុវិស័យរបស់ **ស.ឧ.ក.**

- តំណាងឱ្យ **ស.ឧ.ក.** ក្នុងទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន សមាគម អង្គការមិនមែនរដ្ឋាភិបាល ក្នុងស្រុក និងបរទេស ព្រមទាំងវិស័យឯកជននានា
- តំណាងឱ្យ **ស.ឧ.ក.** ក្នុងការចុះហត្ថលេខាលើរាល់ឯកសារ សេចក្តីសម្រេច កិច្ចសន្យា និងលិខិតគតិយុត្តនានាទាក់ទងនឹងកិច្ចការរបស់ **ស.ឧ.ក.**
- តំណាងឱ្យ **ស.ឧ.ក.** ក្នុងការស្វែងរក និងកៀរគរធនធាន និងទ្រព្យសម្បត្តិ ដើម្បីជាប្រយោជន៍របស់ **ស.ឧ.ក.**
- ត្រួតពិនិត្យលើការអនុវត្តគម្រោងចំណូល និងចំណាយទាំងអស់របស់ **ស.ឧ.ក.**
- ណែនាំ តម្រង់ទិស និងផ្តល់យោបល់ជូនដល់ថ្នាក់ដឹកនាំ នៃរចនាសម្ព័ន្ធដឹកនាំរបស់ **ស.ឧ.ក.** តាមការចាំបាច់។

តាមការចាត់តាំងរបស់ប្រធានក្រុមប្រឹក្សាភិបាល អនុប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាល អាចត្រូវបានប្រគល់ភារកិច្ចដឹកនាំ គ្រប់គ្រង សម្របសម្រួល និងត្រួតពិនិត្យផែនការងារ នៃរចនាសម្ព័ន្ធដឹកនាំនានារបស់ **ស.ឧ.ក.**។

## ផ្នែកទី ៤
## គណៈកម្មការជំនាញ

### ប្រការ ៣១._ គណៈកម្មការជំនាញ

**ស.ឧ.ក.** មានគណៈកម្មការជំនាញ ចំនួន ៤ (បួន) ដូចខាងក្រោម៖

- គណៈកម្មការសមាជិកភាព វិន័យ និងក្រមសីលធម៌
- គណៈកម្មការកិច្ចការច្បាប់
- គណៈកម្មការរដ្ឋបាល និងហិរញ្ញវត្ថុ
- គណៈកម្មការទំនាក់ទំនងសាធារណៈ និងអន្តរជាតិ។

### ប្រការ ៣២._ សមាសភាពគណៈកម្មការជំនាញ

ប្រធានគណៈកម្មការជំនាញ ត្រូវជ្រើសរើសចេញពីអនុប្រធាន ឬសមាសភាពក្រុមប្រឹក្សាភិបាល ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

សមាសភាពផ្សេងទៀតនៃគណៈកម្មការជំនាញ ត្រូវជ្រើសរើសចេញពីសមាសភាពក្រុមប្រឹក្សាភិបាល ឬសមាជិកសកម្ម នៃ**ស.ឧ.ក.** ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

សមាសភាពគណៈកម្មការជំនាញ និងការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការជំនាញ ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ **ស.ឧ.ក.**។

## ផ្នែកទី ៥
## អគ្គលេខាធិការដ្ឋាន

### ប្រការ ៣៣._ អគ្គលេខាធិការដ្ឋាន

អគ្គលេខាធិការដ្ឋាន គឺជាសេនាធិការលើកិច្ចការរដ្ឋបាល បច្ចេកទេស និងទទួលបន្ទុកការងារប្រចាំថ្ងៃរបស់ **ស.ឧ.ក.**។ ចំពោះ ការរៀបចំ និងការប្រព្រឹត្តទៅ នៃអគ្គលេខាធិការដ្ឋាន ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ **ស.ឧ.ក.**។

អគ្គលេខាធិការដ្ឋាន ត្រូវដឹកនាំដោយអគ្គលេខាធិការ ១ (មួយ) រូប និងអាចមានអគ្គលេខាធិការរង មួយចំនួនជាជំនួយការ ដែលត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

នាយកដ្ឋានចំណុះ នៃអគ្គលេខាធិការដ្ឋាន ត្រូវដឹកនាំដោយប្រធាន ១ (មួយ) រូប និងអាចមានអនុប្រធាន មួយចំនួនជាជំនួយការ ដែលត្រូវតែងតាំងដោយប្រធាន **ស.ឧ.ក.** តាមសំណើរបស់អគ្គលេខាធិការ។

បុគ្គលិក នៃអគ្គលេខាធិការដ្ឋាន ត្រូវតែងតាំងដោយប្រធាន **ស.ឧ.ក.** តាមសំណើរបស់អគ្គលេខាធិការ។

## ជំពូកទី៥
## ធនធាន និងទ្រព្យសម្បត្តិ

### ប្រការ ៣៤._ ធនធាន និងទ្រព្យសម្បត្តិ

ធនធាន និងទ្រព្យសម្បត្តិរបស់ **ស.ឧ.ក.** មានប្រភពបានមកពី៖

- ភាគទាន ឬវិភាគទាន ឬបរិវិសទានរបស់សមាជិក **ស.ឧ.ក.**
- ធនធាន និងទ្រព្យសម្បត្តិផ្ទាល់របស់**ស.ឧ.ក.**
- អំណោយស្របច្បាប់ពីរូបវន្តបុគ្គល ឬនីតិបុគ្គល
- ចំណូលពីប្រភពស្របច្បាប់ផ្សេងៗទៀត។

បែបបទ និងនីតិវិធី នៃការគ្រប់គ្រង និងការចាត់ចែងធនធាន និងទ្រព្យសម្បត្តិ ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ **ស.ឧ.ក.**។

### ប្រការ ៣៥._ ចំណូល និងចំណាយរបស់ស.ឧ.ក.

រាល់ចំណូល និងចំណាយររបស់ **ស.ឧ.ក.** ត្រូវគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាល និងប្រធាន **ស.ឧ.ក.** ដោយមានគណៈកម្មការរដ្ឋបាល និងហិរញ្ញវត្ថុជាសេនាធិការ។ រាល់ចំណូល ត្រូវបញ្ចូលក្នុងគណនីធនាគាររបស់**ស.ឧ.ក.**។ រាល់គម្រោងចំណាយ ត្រូវមានការយល់ព្រមជាមុនពីក្រុមប្រឹក្សាភិបាល និងប្រធាន **ស.ឧ.ក.**។

បែបបទ និងនីតិវិធីនៃការគ្រប់គ្រង និងការចាត់ចែងចំណូល និងចំណាយ ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ **ស.ឧ.ក.**។

## ជំពូកទី ៦
## ការផ្លាស់ប្តូរ ឬការធ្វើវិសោធនកម្មលក្ខន្តិកៈ និងការរំលាយ ស.ឧ.ក.

### ប្រការ ៣៦._ ការផ្លាស់ប្តូរ ឬការធ្វើវិសោធនកម្មលក្ខន្តិកៈ

លក្ខន្តិកៈរបស់ **ស.ឧ.ក.** អាចធ្វើការផ្លាស់ប្តូរ ឬធ្វើវិសោធនកម្មបាន តាមសំណើរបស់ប្រធាន **ស.ឧ.ក.** ឬតាមសំណើក្នុងចំនួន ២/៣ (ពីរភាគបី) នៃសមាសភាពក្រុមប្រឹក្សាភិបាល។

ការផ្លាស់ប្តូរ ឬការធ្វើវិសោធនកម្មលក្ខន្តិកៈ ជាសមត្ថកិច្ចរបស់សន្និបាត។

### ប្រការ ៣៧._ ការរំលាយ ស.ឧ.ក.

ការរំលាយ **ស.ឧ.ក.** អាចធ្វើឡើងបាន តាមសំណើរបស់ប្រធាន **ស.ឧ.ក.** ឬតាមសំណើក្នុងចំនួន ២/៣ (ពីរភាគបី) នៃសមាសភាពក្រុមប្រឹក្សាភិបាល។ ការរំលាយ **ស.ឧ.ក.** ជាសមត្ថកិច្ចរបស់សន្និបាត។

ក្រោយពេល **ស.ឧ.ក.** ត្រូវបានប្រកាសរំលាយ រាល់ធនធាន និងទ្រព្យសម្បត្តិរបស់ **ស.ឧ.ក.** ដែលនៅសល់ក្រោយពីការជម្រះរាល់បំណុល នឹងត្រូវចាត់ចែង និងផ្ទេរទៅឱ្យមូលនិធិសប្បុរសធម៌ ក្រោមរូបភាពជាអំណោយ។ បុគ្គលិក និងសមាជិក **ស.ឧ.ក.** ក៏ត្រូវរំលាយផងដែរ។

## ជំពូកទី ៧
## អន្តរប្បញ្ញត្តិ

**ប្រការ ៣៨._**

ឧកញ៉ាគ្រប់រូបដែលបានចូលជាសមាជិកមុនការចូលជាធរមាននៃលក្ខន្តិកៈនេះ អាចរក្សាសិទ្ធិ និងអត្ថប្រយោជន៍នានាដែលទទួលបានកន្លងមក ហើយត្រូវបំពេញរាល់កាតព្វកិច្ច និងភារកិច្ចកំណត់ក្នុងលក្ខន្តិកៈនេះ។

សមាជិកស្ថាបនិក នៃ**ស.ឧ.ក.**ទាំង២៧ (ម្ភៃប្រាំពីរ) រូប ត្រូវទទួលបានជាស្វ័យប្រវត្តិនូវបុព្វសិទ្ធិជា "**គ្រូវិទ្យាចារ្យ**" របស់សមាគមអស់មួយជីវិត។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**ប្រការ ៣៩._**

រាល់បទប្បញ្ញត្តិទាំងឡាយណារបស់**ស.ឧ.ក.** ដែលមានខ្លឹមសារផ្ទុយនឹងលក្ខន្តិកៈនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៤០._**

**ស.ឧ.ក.** ត្រូវធ្វើសកម្មភាពរបស់ខ្លួនស្របតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល លិខិតបទដ្ឋានគតិយុត្តនានាជាធរមាន និងលក្ខន្តិកៈរបស់ខ្លួនដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ។

**ប្រការ ៤១._**

លក្ខន្តិកៈនេះ ត្រូវបានអនុម័តដោយសន្និបាតវិសាមញ្ញ ដែលបានប្រារព្ធធ្វើឡើងនាថ្ងៃទី២២ ខែកញ្ញា ឆ្នាំ ២០២២ និងមានសុពលភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ១២រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២

**ជ.ក្រុមប្រឹក្សាភិបាល**

**ប្រធាន**

**អ្នកឧកញ៉ា លី យ៉ុងផាត់**

លក្ខន្តិកៈ តម្កល់

បានតម្កល់ទុកលក្ខន្តិកៈ
របស់
សមាគមឧកញ៉ាកម្ពុជា
ដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ តាមប្រកាស
លេខៈ ៤៧៥៩.ប្រ.ក ចុះថ្ងៃទី២៥ខែតុលា ឆ្នាំ ២០២២។
រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែតុលា ឆ្នាំ ២០២២
នាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ
ប្រធាន

ឈឹម ភាន

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ឧបសម្ព័ន្ធទី១

## សមាជិកស្ថាបនិក នៃសមាគមឧកញ៉ាកម្ពុជា

| បញ្ជីរាយនាមសមាជិកស្ថាបនិក នៃសមាគមឧកញ៉ាកម្ពុជា | | | |
|---|---|---|---|
| ១ | អ្នកឧកញ៉ា លី យ៉ុងផាត់ | ២ | អ្នកឧកញ៉ា លី ហួរ |
| ៣ | ឧកញ៉ា ថៃ ជាហួត | ៤ | អ្នកឧកញ៉ា ឈាង យុន |
| ៥ | ឧកញ៉ា ហេង ឡុង | ៦ | អ្នកឧកញ៉ា សៀ ឫទ្ធី |
| ៧ | អ្នកឧកញ៉ា ឈាង ម៉េង | ៨ | ឯកឧត្តមឧកញ៉ា ម៉ុង ឫទ្ធី |
| ៩ | ឧកញ៉ា ទិញ ហ៊ួរ | ១០ | ឧកញ៉ា ផៃ ហុកឈួន |
| ១១ | ឧកញ៉ា កុក អាន | ១២ | ឧកញ៉ា ហាន់ ឃៀង |
| ១៣ | លោកជំទាវឧកញ៉ា អ៊ាន អេឡែន | ១៤ | លោកជំទាវឧកញ៉ា ហុង ស៊ួន ស៊ីគង់ទ្រីវ |
| ១៥ | ឧកញ៉ា សុខ ឆេង | ១៦ | ឧកញ៉ា ផាត់ ប៊ុន |
| ១៧ | ឧកញ៉ា តែ អ៊ីឆែ | ១៨ | ឧកញ៉ា ហ៊ុន ឡាក់ |
| ១៩ | ឧកញ៉ា ធីវ ម៉េងហ៊ុយ | ២០ | ឧកញ៉ាវេជ្ជបណ្ឌិត តាន់ គីមមេង |
| ២១ | ឧកញ៉ាបណ្ឌិត គីម ហ៊ាង | ២២ | ឧកញ៉ា គង់ សាង |
| ២៣ | ឧកញ៉ា អ៊ុន ភួត | ២៤ | ឧកញ៉ា ធី ពិសិដ្ឋ |
| ២៥ | ឧកញ៉ា ជៀម ផែន | ២៦ | ឧកញ៉ា ឡាច ភាង |
| ២៧ | ឧកញ៉ា ហេង សៀ | | |

ថ្ងៃព្រហស្បតិ៍ ១២រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២

ជ.ក្រុមប្រឹក្សាភិបាល

ប្រធាន

អ្នកឧកញ៉ា លី យ៉ុងផាត់

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ឧបសម្ព័ន្ធទី២

## សញ្ញាសម្គាល់ និងគំរូត្រា

**ក.អំពីសញ្ញាសម្គាល់**

សញ្ញាសម្គាល់ **ស.ឧ.ក.** មានអត្ថន័យដូចខាងក្រោម៖

- **ក្បាច់ភ្ញីទេសពណ៌មាសព័ទ្ធជុំវិញស្រះពេញតួ** “**ឧ**”÷ តំណាងឱ្យវប្បធម៌ខ្មែរ និងភាពខ្ពង់ខ្ពស់ អង់អាច។
- **ក្បាលហង្សពណ៌មាសជាមួយស្រះពេញតួ** “**ឧ**”÷ តំណាងឱ្យសភាវៈល្អថ្លៃថ្លា ភាពអង់អាច មោះមុត និងមេត្តាធម៌។
- **ក្បាច់ភ្ញីទេសពណ៌មាស ដែលមានរូបរាងដូចផ្កិតព័ទ្ធជុំវិញស្រះពេញតួ** “**ឧ**”÷ តំណាងឱ្យការទំនាក់ទំនង និងកិច្ចសហការជាមួយ **ស.ឧ.ក.** ជួយដល់ប្រជាជនក្រីក្រ និងជាចំណែកមួយជួយដល់ប្រទេសជាតិឱ្យបានថ្កុំថ្កើង។
- **ក្បាច់ភ្ញីទេសពណ៌មាស ពីក្រោមខ្សែបូណ៌**÷ តំណាងឱ្យចិត្តសប្បុរសធម៌ និងការជួយលើកតម្កើងប្រទេសជាតិ។
- **ក្បាច់ត្របកឈូកពណ៌មាស ដែលនៅចំកណ្ដាលនៅខាងក្រោមនៃស្រះពេញតួ** “**ឧ**”÷ តំណាងឱ្យការកកើត សច្ចៈភាព មេត្តាធម៌ និងការប្រព្រឹត្តអំពើល្អ។
- **ខ្សែបូណ៌ពណ៌មាស ទ្រពីក្រោមមានចារឹកអក្សរឡាតាំងជាភាសាខ្មែរ ពណ៌ស ថា “សមាគមឧកញ៉ាកម្ពុជា**”÷ តំណាងឱ្យការចូលរួមគាំទ្រ និងកិច្ចសហប្រតិបត្តិការពី **ស.ឧ.ក.** ក្នុងការជួយដល់ប្រជាជនកម្ពុជា ដោយមិនគិតពីប្រាក់ចំណេញ និងការលះបង់ដល់វិសេសវិសាលដល់ប្រទេសជាតិ។

## ខ.អំពីតំរូត្រា

ត្រា **ស.ឧ.ក.** ៖

- ត្រានេះមានអង្កត់ផ្ចិតទំហំ ៣,៤ (បីក្បៀសបួន) សង់ទីម៉ែត្រ និងត្រូវប្រើទឹកល័ក្ខពណ៌ខៀវ។
- រង្វង់ខាងក្រៅផ្នែកខាងលើសរសេរឈ្មោះ “**សមាគមឧកញ៉ាកម្ពុជា**” ជាអក្សរខ្មែរដោយប្រើពុម្ពអក្សរខ្មែរយូនីកូដ Khmer MEF2 ជាប្រភេទពុម្ពអក្សរ “**មូល**”។
- រង្វង់ខាងក្រៅផ្នែកខាងក្រោមសរសេរឈ្មោះ “**CAMBODIAN OKNHA ASSOCIATION**” ជាអក្សរអង់គ្លេសដោយប្រើពុម្ពអក្សរ Book Antiqua ។
- ចន្លោះអក្សរខ្មែរ និងអក្សរអង់គ្លេស មានក្បាច់ផ្កាចាន់ ដូចមានភ្ជាប់ក្នុងរូប។
- ផ្នែកកណ្ដាលមានដាក់សញ្ញាសម្គាល់ **ស.ឧ.ក.** ដូចដែលបានកំណត់ក្នុងចំណុច ក នៃឧបសម្ព័ន្ធទី២ នៃលក្ខន្តិកៈនេះ។

ថ្ងៃព្រហស្បតិ៍ ១២រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២

**ជ.ក្រុមប្រឹក្សាភិបាល**

**ប្រធាន**

**អ្នកឧកញ៉ា លី យ៉ុងផាត់**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## ឧបសម្ព័ន្ធទី៣

## រចនាសម្ព័ន្ធដឹកនាំ




ថ្ងៃព្រហស្បតិ៍ ១២រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២

ជ.ក្រុមប្រឹក្សាភិបាល

ប្រធាន

អ្នកឧកញ៉ា លី យ៉ុងផាត់

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ឧបសម្ព័ន្ធទី៤

## សមាសភាពក្នុងរចនាសម្ព័ន្ធដឹកនាំ នៃ ស.ឧ.ក.

| ល.រ | នាមត្រកូល និងនាមខ្លួន | តួនាទីក្នុងរចនាសម្ព័ន្ធ | សេចក្តីផ្សេងៗ |
|---|---|---|---|
| ១ | អ្នកឧកញ៉ា លី យ៉ុងផាត់ | ប្រធានក្រុមប្រឹក្សាភិបាល | |
| ២ | អ្នកឧកញ៉ា លី ហួរ | អនុប្រធានក្រុមប្រឹក្សាភិបាល | |
| ៣ | ឧកញ៉ា ថៃ ជាហួត | អនុប្រធានក្រុមប្រឹក្សាភិបាល | |
| ៤ | អ្នកឧកញ៉ា លាង ឃុន | អនុប្រធានក្រុមប្រឹក្សាភិបាល | |
| ៥ | ឧកញ៉ា ហេង ឡុង | អនុប្រធានក្រុមប្រឹក្សាភិបាល | |
| ៦ | អ្នកឧកញ៉ា សៀ ឫទ្ធី | អនុប្រធានក្រុមប្រឹក្សាភិបាល | |
| ៧ | អ្នកឧកញ៉ា លាង ម៉េង | អនុប្រធានក្រុមប្រឹក្សាភិបាល | |
| ៨ | ឯកឧត្តមឧកញ៉ា ម៉ុង ឫទ្ធី | អនុប្រធានក្រុមប្រឹក្សាភិបាល | |
| ៩ | ឧកញ៉ា ទិញ ហ៊ួរ | អនុប្រធានក្រុមប្រឹក្សាភិបាល | |
| ១០ | ឧកញ៉ា ផៃ ហុកឈួន | អនុប្រធានក្រុមប្រឹក្សាភិបាល | |
| ១១ | ឧកញ៉ា គុក អាន | អនុប្រធានក្រុមប្រឹក្សាភិបាល | |
| ១២ | ឧកញ៉ា ហាន់ ឃៀង | អនុប្រធានក្រុមប្រឹក្សាភិបាល | |
| ១៣ | លោកជំទាវឧកញ៉ា អ៊ាន អេឡែន | អនុប្រធានក្រុមប្រឹក្សាភិបាល | |
| ១៤ | លោកជំទាវឧកញ៉ា ហុង ស៊ួន ស៊ីគង់ទ្រីវ | សមាជិកក្រុមប្រឹក្សាភិបាល | |
| ១៥ | ឧកញ៉ា សុខ ឆេង | សមាជិកក្រុមប្រឹក្សាភិបាល | |
| ១៦ | ឧកញ៉ា ផាត់ ប៊ុន | សមាជិកក្រុមប្រឹក្សាភិបាល | |
| ១៧ | ឧកញ៉ា តែ អ៊ីឆែ | សមាជិកក្រុមប្រឹក្សាភិបាល | |
| ១៨ | ឧកញ៉ា ហ៊ុន ឡាក់ | សមាជិកក្រុមប្រឹក្សាភិបាល | |
| ១៩ | ឧកញ៉ា ទីវ ម៉េងហ៊ុយ | សមាជិកក្រុមប្រឹក្សាភិបាល | |
| ២០ | ឧកញ៉ាវេជ្ជបណ្ឌិត តាន់ គីមមេង | សមាជិកក្រុមប្រឹក្សាភិបាល | |
| ២១ | ឧកញ៉ាបណ្ឌិត គីម ហ៊ាង | សមាជិកក្រុមប្រឹក្សាភិបាល | |
| ២២ | ឧកញ៉ា គង់ សាង | សមាជិកក្រុមប្រឹក្សាភិបាល | |

| | | | | |
|---|---|---|---|---|
| ២៣ | ឧកញ៉ា | **អ៊ុន ក្ងត** | សមាជិកក្រុមប្រឹក្សាភិបាល | |
| ២៤ | ឧកញ៉ា | **ទី ពិសិដ្ឋ** | សមាជិកក្រុមប្រឹក្សាភិបាល | |
| ២៥ | ឧកញ៉ា | **ជៀម ផែន** | សមាជិកក្រុមប្រឹក្សាភិបាល | |
| ២៦ | ឧកញ៉ា | **ឡាច ភាង** | សមាជិកក្រុមប្រឹក្សាភិបាល | |
| ២៧ | ឧកញ៉ា | **ហេង សៀ** | សមាជិកក្រុមប្រឹក្សាភិបាល | |

ថ្ងៃព្រហស្បតិ៍ ១២រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២

**ជ.ក្រុមប្រឹក្សាភិបាល**

**ប្រធាន**

**អ្នកឧកញ៉ា លី យ៉ុងផាត់**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សមាគមឧកញ៉ាកម្ពុជា**

លេខ ៩២២-០១ ស.ឧ.ក.

**សូមគោរពជូន**

**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**កម្មវត្ថុ** ÷ ស្តីពីសំណើសុំចុះបញ្ជី **សមាគមឧកញ៉ាកម្ពុជា** (ស.ឧ.ក.) ឡើងវិញ ក្នុងបញ្ជីសមាគមនៅក្រសួងមហាផ្ទៃ។

**យោង** ÷- ព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

- លិខិតលេខ ២១៣៨ សជណ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៥ របស់ក្រសួងមហាផ្ទៃ
- លទ្ធផល នៃសន្និបាតវិសាមញ្ញរបស់សមាគមឧកញ៉ាកម្ពុជា ដែលបានប្រារព្ធធ្វើឡើង កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **សម្តេចក្រឡាហោម** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា **សមាគមឧកញ៉ាកម្ពុជា** (ស.ឧ.ក.) ត្រូវបានក្រសួងមហាផ្ទៃសម្រេចអនុញ្ញាតឱ្យចុះឈ្មោះក្នុងបញ្ជីសមាគមតាមរយៈលិខិតលេខ ២១៣៨ សជណ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៥ របស់ក្រសួងមហាផ្ទៃ ដោយបច្ចុប្បន្នមានអាសយដ្ឋាននៃទីស្នាក់ការកណ្តាលស្ថិតនៅសណ្ឋាគារភ្នំពេញ អគារលេខ៥៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ កាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២ **សមាគមឧកញ៉ាកម្ពុជា** (**ស.ឧ.ក.**) បានប្រារព្ធសន្និបាតវិសាមញ្ញ ដើម្បីពិភាក្សា និងបោះឆ្នោតអនុម័តលើឯកសារមួយចំនួន រួមមាន៖ ១.សេចក្តីព្រាងលក្ខន្តិកៈថ្មីរបស់ **ស.ឧ.ក.** ២.សញ្ញាសម្គាល់ និងត្រាថ្មីរបស់ **ស.ឧ.ក.** និង៣.គម្រូឯកសាររដ្ឋបាលរបស់ **ស.ឧ.ក.**។ ទន្ទឹមនេះដែរ សមាជិក សមាជិកានៃសន្និបាតវិសាមញ្ញ **ស.ឧ.ក.** បានឯកភាពជាឯកច្ឆ័ន្ទអនុញ្ញាតឱ្យសមាគមរៀបចំសំណុំឯកសារសុំចុះបញ្ជី **សមាគមឧកញ៉ាកម្ពុជា** (ស.ឧ.ក.) ឡើងវិញក្នុងបញ្ជីសមាគមនៅក្រសួងមហាផ្ទៃ ដើម្បីឱ្យស្របតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** មេត្តាពិនិត្យ និងសម្រេចដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់។

សូម **សម្តេចក្រឡាហោម** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទ។

ថ្ងៃព្រហស្បតិ៍ ១២រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២

**ជ.ក្រុមប្រឹក្សាភិបាល**

**ប្រធាន**

**អ្នកឧកញ៉ា លី យ៉ុងផាត់**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ: ៧១ ៣៨ អនក៧

រាជធានីភ្នំពេញ,ថ្ងៃទី១៩ ខែ៩៣ ឆ្នាំ២០១៥

**ជម្រាបមក**
**ឧកញ៉ា លី យ៉ុងផាត់**
**ប្រធានសមាគមឧកញ៉ាកម្ពុជា**

**<u>កម្មវត្ថុ</u>** : ស្តីពីការសុំចុះឈ្មោះ **សមាគមឧកញ៉ាកម្ពុជា** ក្នុងបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល នៅក្រសួងមហាផ្ទៃ។

**<u>យោង</u>** : លិខិតលេខ ០០១/១៥ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ស្តីពីការសុំចុះឈ្មោះ សមាគមឧកញ៉ាកម្ពុជា ក្នុងបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល នៅក្រសួងមហាផ្ទៃ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបប្រធានថា ក្រសួងមហាផ្ទៃ បានយល់ព្រមចុះឈ្មោះ សមាគមឧកញ៉ាកម្ពុជា ដែលមានអាសយដ្ឋាន នៃទីស្នាក់ការកណ្តាលតាំងនៅជាន់ទី៥នៃមជ្ឈមណ្ឌលពាណិជ្ជកម្មអ៊ែតរូត ផ្ទះលេខ២៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ក្នុងបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលតាមសំណើ។

សមាគមឧកញ៉ាកម្ពុជា ត្រូវអនុវត្តតាមលក្ខន្តិកៈដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ និងធ្វើសកម្មភាពការងារក្នុងក្របខណ្ឌជាសមាគមអព្យាក្រឹត មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើសកម្មភាពបម្រើឲ្យគណបក្សនយោបាយ មិនធ្វើជាឧបករណ៍គណបក្សនយោបាយ និងមិនស្វែងរកប្រាក់កម្រៃជាឯកជន។

អាស្រ័យហេតុនេះ សូមប្រធានជ្រាបជាព័ត៌មាន និងចាត់ចែងអនុវត្តតាមការគួរ។

ជ - រដ្ឋមន្ត្រី
រដ្ឋលេខាធិការ

ប៉ុល លឹម

**<u>ចម្លងជូន</u> ៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "<u>ដើម្បីជូនជ្រាប</u>"
- សាលារាជធានីភ្នំពេញ
  "<u>ដើម្បីមុខការ</u>"
- ឯកសារ - កាលប្បវត្តិ

ទីស្តីការក្រសួងមហាផ្ទៃ លេខ ២៧៥ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣
ទូរសារ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣ e-mail: moi@interior.gov.kh web: www.interior.gov.kh

# សមាគមឧកញ៉ាកម្ពុជា

**Cambodian Oknha Association**

អាសយដ្ឋាន: នៅលេខ៥៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

## សេចក្ដីសម្រេចរបស់សន្និបាត និងក្រុមប្រឹក្សាភិបាល

- យោងប្រការ ២៥ នៃលក្ខន្តិកៈសមាគមឧកញ៉ាកម្ពុជា (តទៅនេះហៅថា "**ស.ឧ.ក.**")

យើងជាសមាជិក សមាជិកានៃ **ស.ឧ.ក.** និងនៃក្រុមប្រឹក្សាភិបាល សម្រេចដាក់ចេញដូចខាងក្រោម៖

១. អនុម័តវិសោធនកម្មលើលក្ខន្តិកៈ **ស.ឧ.ក.** ដែលខ្លឹមសារទាំងស្រុងមានភ្ជាប់ជាឧបសម្ព័ន្ធទី១។

២. អនុម័តទៅលើរូបសញ្ញា និងត្រារបស់ **ស.ឧ.ក.** ដែលមានកំណត់ក្នុងឧបសម្ព័ន្ធទី២ និងឧបសម្ព័ន្ធទី៣។

៣. អនុម័តទៅលើគម្រូឯកសាររដ្ឋបាលរបស់ **ស.ឧ.ក.** (នាមប័ណ្ណ ស្រោមសំបុត្រ ក្បាលលិខិត ជាដើម)។ និង

៤. ផ្ដល់សិទ្ធិដល់អ្នកឧកញ៉ា **លី យ៉ុងផាត់** ជាប្រធាន **ស.ឧ.ក.** ដើម្បីធ្វើជាអ្នកតំណាងស្របច្បាប់របស់ **ស.ឧ.ក.** ក្នុងការចុះហត្ថលេខា ទៅលើលក្ខន្តិកៈ **ស.ឧ.ក.** និងឯកសារពាក់ព័ន្ធ ព្រមទាំងធ្វើរាល់សកម្មភាពចាំបាច់នានាដែលតម្រូវដោយក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ។

សេចក្ដីសម្រេចរបស់សន្និបាត និងក្រុមប្រឹក្សាភិបាលនេះ មានសុពលភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

សេចក្ដីសម្រេចរបស់សន្និបាត និងក្រុមប្រឹក្សាភិបាលនេះ ធ្វើឡើងជាភាសាខ្មែរចំនួន ៤ (បួន) ច្បាប់ ហើយគ្រប់ច្បាប់ទាំងអស់ដាក់រួមគ្នាបង្កើតជាលិខិតូបករណ៍តែមួយ និងដូចៗគ្នា។

រាជធានីភ្នំពេញ ថ្ងៃទី...២៦... ខែ...កញ្ញា... ឆ្នាំ២០២២

អ្នកឧកញ៉ា **លី យ៉ុងផាត់**

អ្នកឧកញ៉ា **លី ហួរ**

ឧកញ៉ា **ថៃ ជាហួត**

អ្នកឧកញ៉ា **លាង ឃុន**

អ្នកឧកញ៉ា **ហេង ឡុង**

អ្នកឧកញ៉ា **សៀ ឫទ្ធី**

អ្នកឧកញ៉ា **លាង ម៉េង**

ឧកញ៉ា **ទិញ ហ៊ួរ**

នាយកដ្ឋាន
កិច្ចការសមាគម និងគណបក្សនយោបាយ

ឧកញ៉ា **ផៃ ហុកឈួន**

ឧកញ៉ា **សុខ ឆេង**

ឧកញ៉ា **ហាន់ ឃៀង**

ឧកញ៉ា **ផាត់ ម៉ុន**

ឧកញ៉ា **តែ អ៊ុំឆែ**

ឧកញ៉ា **ហ៊ុន ឡាក់**

ឧកញ៉ា **ធីវ ម៉េងហ៊ុយ**

ឧកញ៉ា វេជ្ជបណ្ឌិត **តាន់ គីមមេង**

ឧកញ៉ា បណ្ឌិត **គីម ហ៊ាង**

ឧកញ៉ា **គង់ សាង**

ឧកញ៉ា **អ៊ុន ភួត**

លោកជំទាវឧកញ៉ា **អ៊ាន អេឡែន**

នាយកដ្ឋាន
កិច្ចការសមាគម និងគណបក្សនយោបាយ

លោកជំទាវឧកញ៉ា **ហុង ស៊ួន ស៊ីគង់ធ្រីច**

ឧកញ៉ា **ធី ពិសិដ្ឋ**

ឧកញ៉ា **ជៀម ផែន**

ឧកញ៉ា ................................

ឧកញ៉ា ................................

ឧកញ៉ា ................................

ឧកញ៉ា ................................

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សមាគមឧកញ៉ាកម្ពុជា
Cambodian Oknha Association
លេខៈ ៩៧.០២ ស.ឧ.ក

# សេចក្តីសម្រេច
## ស្តីពី
## ការចាត់តាំងសមាសភាពក្រុមប្រឹក្សាភិបាល នៃសមាគមឧកញ៉ាកម្ពុជា

នាយកដ្ឋាន ប្រតិបត្តិការសមាគម និងគណបក្សនយោបាយ

## សមាគមឧកញ៉ាកម្ពុជា

- យោងព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- យោងលិខិតលេខ ២១៣៨ សជណ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៥ របស់ក្រសួងមហាផ្ទៃ
- យោងតាមស្មារតី នៃលទ្ធផលសន្និបាតវិសាមញ្ញរបស់សមាគមឧកញ៉ាកម្ពុជា ដែលបានប្រារព្ធធ្វើឡើងកាលពីថ្ងៃទី២២ ខែកញ្ញាឆ្នាំ២០២២.

## សម្រេច

**ប្រការ ១** .- ត្រូវបានចាត់តាំងសមាសភាពក្រុមប្រឹក្សាភិបាល នៃសមាគមឧកញ៉ាកម្ពុជា ស្របតាមលទ្ធផល នៃសន្និបាតវិសាមញ្ញដែលបានប្រារព្ធធ្វើឡើងកាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២ ដោយបានសម្រេចជាឯកច្ឆ័ន្ទក្នុងការជ្រើសរើសសមាជិក និងសមាជិកា នៃស.ឧ.ក. ចំនួន២៧ (ម្ភៃប្រាំពីរ)រូប ឱ្យបំពេញមុខតំណែងជាប្រធាន អនុប្រធាន និងជាសមាជិក ដូចមានរាយនាមខាងក្រោមៈ

| | | | |
|---|---|---|---|
| ១. | អ្នកឧកញ៉ា | **លី យ៉ុងផាត់** | ជាប្រធាន |
| ២. | អ្នកឧកញ៉ា | **លី ហួរ** | ជាអនុប្រធាន |
| ៣. | ឧកញ៉ា | **ថៃ ជាហួត** | ជាអនុប្រធាន |
| ៤. | អ្នកឧកញ៉ា | **លាង ឃុន** | ជាអនុប្រធាន |
| ៥. | ឧកញ៉ា | **ហេង ឡុង** | ជាអនុប្រធាន |
| ៦. | អ្នកឧកញ៉ា | **សៀ ឬទ្ធី** | ជាអនុប្រធាន |
| ៧. | អ្នកឧកញ៉ា | **លាង ម៉េង** | ជអនុប្រធាន |
| ៨. | ឯកឧត្តមឧកញ៉ា | **ម៉ុង ឬទ្ធី** | ជាអនុប្រធាន |
| ៩. | ឧកញ៉ា | **ចិញ ហ៊ីរ** | ជាអនុប្រធាន |
| ១០. | ឧកញ៉ា | **ផៃ ហុកឈួន** | ជាអនុប្រធាន |
| ១១. | ឧកញ៉ា | **ភុក អាន** | ជាអនុប្រធាន |
| ១២. | ឧកញ៉ា | **ហាន់ ឃៀង** | ជាអនុប្រធាន |
| ១៣. | លោកជំទាវឧកញ៉ា | **អ៊ិន អេឡែន** | ជាអនុប្រធាន |
| ១៤. | លោកជំទាវឧកញ៉ា | **ហុង ស៊ួន ស៊ីគង់ទ្រីង** | ជាសមាជិក |
| ១៥. | ឧកញ៉ា | **សុខ ឆេង** | ជាសមាជិក |

១៦. ឧកញ៉ា **ផាត់ ម៉ឹន** ជាសមាជិក

១៧. ឧកញ៉ា **តែ អ៊ីនែ** ជាសមាជិក

១៨. ឧកញ៉ា **ហ៊ិន ឡាក់** ជាសមាជិក

១៩. ឧកញ៉ា **ទីវ ម៉េងហ៊ុយ** ជាសមាជិក

២០. ឧកញ៉ាវេជ្ជបណ្ឌិត **តាន់ គីមមេង** ជាសមាជិក

២១. ឧកញ៉ាបណ្ឌិត **គីម ហ៊ាង** ជាសមាជិក

២២. ឧកញ៉ា **គង់ សាង** ជាសមាជិក

២៣. ឧកញ៉ា **អ៊ីន ភួត** ជាសមាជិក

២៤. ឧកញ៉ា **ទី ពិសិដ្ឋ** ជាសមាជិក

២៥. ឧកញ៉ា **ជៀម ផែន** ជាសមាជិក

២៦. ឧកញ៉ា **ឡាង ភាង** ជាសមាជិក

២៧. ឧកញ៉ា **ហេង សៀ** ជាសមាជិក។

**ប្រការ ២**.- អ្នកឧកញ៉ា ឧកញ៉ា ដូចមានឈ្មោះក្នុងប្រការ១ខាងលើ ត្រូវទទួលខុសត្រូវក្នុងការបំពេញតួនាទី និងភារកិច្ច ស្របតាមបទប្បញ្ញត្តិ នៃលក្ខន្តិកៈ**ស.ឧ.ក**។

**ប្រការ ៣** .- សេចក្តីសម្រេចនេះ មានសុពលភាពគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១២រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២

**ជ.ក្រុមប្រឹក្សាភិបាល**

**ប្រធាន**

**អ្នកឧកញ៉ា លី យ៉ុងផាត់**

**ចម្លងជូន៖**

- គ្រប់គណៈកម្មការជំនាញ
- អគ្គលេខាធិការដ្ឋាន
- ដូចប្រការ ២

**(ដើម្បីអនុវត្ត)**

- ឯកសារ កាលប្បវត្តិ

នាយកដ្ឋានកិច្ចការសមាជិក និងគណបក្សនយោបាយ